ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# ដំណាំស្វាយ



ផលិតដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ឆ្នាំ២០១៦






**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៨៥

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - **Department of Agricultural Extension**

**គេហទំព័រ** : **http://www.maff.gov.kh**

# សៀវភៅ

# ស្តីពី

# ដំណាំស្វាយ


## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម



បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ផលិតដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



រក្សាសិទ្ធដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីដំណាំស្វាយ

## I. ទីប្រឹក្សាផ្តល់យោបល់:

១. បណ្ឌិត **ម៉ាក់ សឿន** អគ្គនាយកដ្ឋានកសិកម្ម

២. បណ្ឌិត **ម៉ៅ មីនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **ប៉ែន ឧុទ្ធី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. លោក **គឹម ដារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## III. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **ពេជ សុខន្ថារ៉ា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

២. លោក **ហួច ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៣. កញ្ញា **ចាន់ សធី** នាយកដ្ឋានសារប្បកម្ម និងដំណាំរួមផ្សំ

៤. លោក **កេត សំអាត** នាយកដ្ឋានសារប្បកម្ម និងដំណាំរួមផ្សំ

## មាតិកា

ទំព័រ


I. បច្ចេកទេសដាំដុះ....................................០២

១. ការបន្តពូជ................................០២

២.ការជ្រើសរើសពូជ.......................០៣

៣.ការជ្រើសរើសទីកន្លែងដាំដុះ.........៣

៤. ការរៀបចំដី...............................៤

៥.ការជីករណ្ដៅដាំស្វាយ.................៥

៦. ការដាំដុះ.................................៦

៧. ការថែទាំ.................................៧

II. ជំងឺ និងសត្វល្អិតបំផ្លាញដំណាំស្វាយ........១០

១.ជំងឺលើដំណាំស្វាយ....................១០

២. សត្វល្អិតបំផ្លាញដំណាំស្វាយ.......១៣

III. ការប្រមូលផល....................................២៤



# ដំណាំស្វាយ

ស្វាយជាដំណាំឈើហូបផ្លែមួយប្រភេទ ក្នុងចំណោមប្រភេទឈើហូបផ្លែជាច្រើនទៀត ដែលគេនិយមចូលចិត្តបរិភោគ ទាំងផ្លែស្រស់ និងទុំ

ផ្អែកលើស្ថានភាពជាក់ស្តែងក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ ការបរិភោគផ្លែស្វាយស្រស់ កំពុងទទួលការពេញនិយមខ្លាំងណាស់ពីស្រទាប់យុវវ័យ។ ក្រៅពីនេះផ្លែស្វាយអាចរក្សាទុកបានយូរផងដែរដូចជានៅកន្លែងត្រជាក់ ការយកទៅសម្ងួតដាក់ក្នុងកំប៉ុង ការធើជាដំណាប់ ធ្វើជាចាហួយ និងអាចធ្វើជាការ៉េមផងដែរ ហើយពិសេសជាងនេះទៅទៀតក្នុងផ្លែស្វាយសម្បូរទៅដោយសារធាតុវីតាមីនជាច្រើនដូចជា វីតាមី A វីតាមីន C និងសារធាតុចិញ្ចឹមជាច្រើនទៀតដូចមានបរិយាយក្នុងតារាងខាងក្រោម៖

## សមាសភាពសារធាតុផ្សំក្នុងស្វាយទម្ងន់១០០ ក្រាម

| ល.រ | សមាសភាពសារធាតុផ្សំ | ខ្នាត | កម្រិតសមាសភាពសារធាតុផ្សំ |
|---|---|---|---|
| ១ | ថាមពល | កាឡូរី | ៦២.១-៦៣.៧ |
| ២ | សំណើម | ក្រាម | ៧៨,៩-៨២,៨ |
| ៣ | ប្រូតេអ៊ីន | ក្រាម | ០.៣៦-០.៤០ |
| ៤ | ខ្លាញ់ | ក្រាម | ០.៣-០,៥៣ |
| ៥ | កាបូអ៊ីដ្រាត | ក្រាម | ១៦,២០-១៧,១៨ |
| ៦ | សរសៃ | ក្រាម | ០,៨៥-១,០៦ |
| ៧ | ផេះ | ក្រាម | ០.៣៤-០.៥២ |
| ៨ | កាលស្យូម | មីលីក្រាម | ៦.១-១២.៨ |

| | | | |
|---|---|---|---|
| ៩ | ផូស្វ័រ | មីលីក្រាម | ៥,៥-១៧,៩ |
| ១០ | ដែក | មីលីក្រាម | ០,២០-០,៦៣ |
| ១១ | មីតាមីនA | មីលីក្រាម | ០,១៣៥-១,៨៧២ |
| ១២ | វីតាមីនB1 (Thiamine) | មីលីក្រាម | ០,០២០-០,០៧៣ |
| ១៣ | រីបូប្លាវីន(Riboflavine) | មីលីក្រាម | ០,០២៥-០,០៦៨ |
| ១៤ | នីយ៉ាស៊ីន | មីលីក្រាម | ០,០២៥-០,៧០៧ |
| ១៥ | វីតាមីន C (អាស៊ីតអាស្កូបិក | មីលីក្រាម | ៧.៨-១៧២,០ |
| ១៦ | ទ្រីបតូហ្វាន | មីលីក្រាម | ៣-៦ |
| ១៧ | មេទីយូនីន | មីលីក្រាម | ៤ |
| ១៨ | លីស៊ីន | មីលីក្រាម | ៣២-៣៧ |

## I. បច្ចេកទេសដាំដុះ

### ១. ការបន្តពូជ

ដំណាំស្វាយត្រូវបានគេដាំដុះដោយសរីរាង្គគ្រាប់ ឬដោយសរីរាង្គតាមរយៈការបណ្ដុះ ផ្សាំ ឬក៏បំបៅជាដើម។ ការបន្តពូជដោយគ្រាប់ គឺជាវិធីមួយដ៏ល្អ ជាការដាំដោយសរីរាង្គបានពីការផ្សាំមែក ព្រោះការដាំដោយគ្រាប់ ដំណាំស្វាយអាចដុះលូតលាស់បានល្អ មិនសូវមានជំងឺឆ្លង ធន់នឹងមជ្ឈដ្ឋានខាងក្រៅ បង្កើតប្រព័ន្ធឫសមានបានមាំល្អ អាចស្រូបយកសារធាតុទឹក និងជីជាតិបានងាយពីក្នុងដី។

#### ❈ ការរៀបដីបណ្ដុះគ្រាប់

មុនពេលបណ្ដុះគ្រាប់ មុនដំបូងត្រូវជ្រើសរើសទីកន្លែងឱ្យបានសមស្របសម្រាប់ធ្វើថ្នាលបណ្ដុះ បន្ទាប់មករៀបចំដីថ្នាលបណ្ដុះឱ្យម៉ត់ល្អដាក់ជីលាមកសត្វក្នុងកម្រិតសមស្របទៅនឹងស្ថានភាពដីនៅក្នុងតំបន់ដាំដុះ។

កូនស្វាយដែលត្រូវយកមកដាំ ត្រូវមានអាយុយ៉ាងតិច ៤ សប្ដាហ៍ បន្ទាប់ពីបណ្ដុះគ្រាប់។

## ២. ការជ្រើសរើសពូជ

គួរធ្វើការជ្រើសពូជស្វាយតាមលក្ខណៈដូចខាងក្រោម៖

- យកផ្លែធំ ហើយទុំល្អ
- គ្រាប់មិនប្រះ ឬបែក
- ជាពូជថ្មី មានដំណុះគ្រាប់ខ្ពស់
- ពូជធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ ជំងឺ និងសត្វបំផ្លា
- ដើមរឹងមាំ មានអាយុវែង។





## ៣.ការជ្រើសរើសទីកន្លែងដាំដុះ

ការជ្រើសរើសទីកន្លែង សម្រាប់ដាំដុះគួរពិចារណាទៅដល់ចំណុចមួយចំនួនដូចខាងក្រោម៖

- ជាប្រភេទដីដែលមានកម្រិត pH ៥,៥-៧,៥
- ជៀសវាងការដាំលើដីដែលមានសារធាតុគីមី អាចបង្កផលប៉ះពាល់ការលូតលាស់របស់ដំណាំ
- ជាប្រភេទដីច្រោះទឹកល្អ មិនដាំទឹក
- ជៀសវាងដាំលើប្រភេទដីដែលមានសារធាតុកំបោរច្រើន ដីសម្បូរថ្ម និងខ្សោះជីជាតិ
- ជាប្រភេទដីនៅជិតប្រភពទឹក ខ្យល់អាកាសអាចផ្លាស់ប្តូរបានល្អ

និងមានពន្លឺគ្រប់គ្រប់គ្រាន់។

## ៤. ការរៀបចំដី

ត្រូវភ្ជួរដីក្នុងជម្រៅពី២០-៣០ សង់ទីម៉ែត្រ មិនត្រូវភ្ជួរដី ក្នុងអំឡុងពេលដីសើមពេក ឬរឹងពេកទេ ព្រោះវាធ្វើឱ្យខូចទម្រង់ដី។ ត្រូវហាលដីឱ្យពី៧-១០ ថ្ងៃ នៅរដូវប្រាំង និងពី១៥-៣០ ថ្ងៃ នៅរដូវវស្សា មុនកាប់រណ្ដៅដាំ។





### ❈ គុណសម្បត្តិនៃការរៀបចំដី

- ធ្វើឱ្យប្រព័ន្ធឫសដុះលូតលាស់បានល្អ
- បង្កើនលទ្ធភាពរបស់ដីក្នុងការជ្រាបទឹកបានល្អ
- ធ្វើឱ្យទឹកភ្លៀង ឬទឹកដែលបានស្រោចស្រព ជ្រាបចុះទៅក្នុងដីបានជ្រៅ
- ការបន្ថយការហូរច្រោះដី
- សម្លាប់សត្វល្អិត និងជំងឺដែលស្នាក់អាស្រ័យនៅក្នុងដី
- ធ្វើឱ្យផ្លែធំល្អ
- បង្កើនទិន្នផលស្វាយ
- បង្កើនសេដ្ឋកិច្ចគ្រួសារដោយសារការប្រមូលផលស្វាយបានយូរ។

# ៥.ការជីករណ្ដៅដាំស្វាយ

ត្រូវជីករណ្ដៅទំហំ ១ ម៉ែត្រ x ១ម៉ែត្រ x ១ម៉ែត្រ ឬយ៉ាងហោចណាស់ ៧៥ សង់ទីម៉ែត្រ x ៧៥ សង់ទីម៉ែត x ៧៥ សង់ទីម៉ែត ព្រោះដំណាំស្វាយត្រូវការដីធូរសម្រាប់ការលូតលាស់ប្រព័ន្ធឫស។

ការជីករណ្ដៅគេត្រូវចែកសណ្ឋានដីជា៣ស្រទាប់ដូចខាងក្រោម៖

- ស្រទាប់ទី១ ជម្រៅ៣០សង់ទីម៉ែត្រ ចុះក្រោមជាស្រទាប់ដែលដែលមានជីជាតិច្រើនជាងគេ ហើយត្រូវដាក់មួយកន្លែង ហើយស្រទាប់ទី២ និងទី៣ មានជម្រៅ៤០ សង់ទីម៉ែត្រ ជាស្រទាប់ដីចុងក្រោយ ដាក់មួយកន្លែងផ្សេងទៀត ធ្វើបែបនេះដើម្បីងាយស្រួលក្នុងការលប់ដីចូលរណ្ដៅវិញ ដើម្បីឱ្យប្រពន្ធឫសអាចស្រូបយកសារធាតុចិញ្ចឹមបានល្អ ។ បន្ទាប់មកចាក់ជីកំប៉ុស្ត និងស្លឹករុក្ខជាតិផ្សេងៗ ដែលពុកផុយចូលទៅក្នុងបាតរណ្ដៅ ប្រមាណ១០-២០ សង់ទីម៉ែត្រ ទើបធ្វើកាតលប់ដី ដែលជាស្រទាប់លើបំផុតបន្ទាប់មកដាក់ជីបន្តទៀតដោយដាក់ដូចការទៅនឹងការដាក់លើកទី១ ដែរ ហើយយកដីស្រទាប់ទី២ ដាក់បន្ទាប់ទៀត ។ ដីស្រទាប់ទី២ នេះគួរដាក់លាយជាមួយជីលាមកសត្វពី៥-១០ សង់ទីម៉ែត្រមុនធ្វើការលប់ដី បន្ទាប់មកទៀតក្រាលដីស្រទាប់ទី៣ និងលប់



ដីស្រទាប់ទី៣នេះ ដោយលាយជាមួយជីកំប៉ុស្តដូចទៅនឹងការលប់ដីស្រទាប់ទី២ ដែរ ។ ការលប់ដីនៅលើរណ្តៅ ត្រូវលប់ជារាង្គខ្នងអណ្តើក បន្ទាប់មកយើងយកឫស្សីមកដោតនៅចំកណ្តាលរណ្តៅដើម្បីងាយស្រួលចំណាំពេលដាំកូន។

ចម្ងាយនៃគម្លាតចន្លោះគុម្ពអាចពី៣-៩ ម៉ែត្រ និងចន្លោះជួរអាចពី៦-៩ ម៉ែត្រ នេះចំពោះការដាំជាលក្ខណៈអាជីវកម្ម ។ ចំពោះការដាំជាលក្ខណៈជាលក្ខណៈគ្រួសារគម្លាតចម្ងាយគុម្ពអាច៩ ម៉ែត្រ ។ គម្លាតចម្ងាយរបស់គុម្ពឬដើមស្វាយ ទាំងការដាំជាលក្ខណៈអាជីវកម្ម និងការដាំជាលក្ខណៈគ្រួសារ ក៏អាស្រ័យទៅតាមប្រភេទពូជផងដែរ។

## ៦. ការដាំដុះ

ត្រូវយកកូនកូនស្វាយរាយតាមរណ្តៅ បន្ទាបមកយកចបជីក ឬចបកាប់កាយចំកណ្តាលរណ្តៅ គឺចំចំណុចដែលយើងបានដោតចំណាំ ដោយបកថង់បណ្តុះស្វាយចេញ ដាក់កូនស្វាយឱ្យឈរត្រង់ បន្ទាប់មកលប់ដីយកចំណារឫស្សីមកដោត ហើយចងផ្តោបកូនស្វាយឱ្យមានជំហ៊រល្អបង្ការកូនស្វាយរលើងពេលមានខ្យល់បក់ខ្លាំង និងជួយឱ្យកូនស្វាយអាចលូតលាស់ប្រព័ន្ធឫសបានល្អ។








## ៧. ការថែទាំ

### ក. ការស្រោចស្រព

ជាទូទៅការស្រោចស្រពដំណាំស្វាយ គេនិយមធ្វើនៅរដូវប្រាំង ព្រោះព្រោះជារដូវខ្វះទឹក ប្រព័ន្ធឫសមិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រូបយកទៅចិញ្ចឹមសរីរាង្គ។ ការស្រោចស្រពមានអត្ថប្រយោជន៍ដូចជាជួយឱ្យរុក្ខជាតិបង្កើតមែកបានច្រើន ចេញផ្កាស្រុះ កាន់ផ្លែបានច្រើន ។ ការស្រោស្រពជាកាប្រសើរគួរធ្វើក្រោយពេលដាក់ជីបំប៉ន ពិសេសក្នុងខែកញ្ញានិងខែតុលា ដើម្បីឱ្យគ្រប់សរីរាង្គស្វាយមានការលូតលាសលឿន។

ការស្រោចស្រពគួរស្វែងយល់ផងដែរ ពីស្ថានភាពដីក្នុងតំបន់ដាំដុះព្រោះសណ្ឋានដីក្នុងតំបន់នីមួយៗមានភាពខុសពីគ្នា តំបន់ខ្លះមានប្រភពទឹក្នុងដីរាក់ និងតំបន់ខ្លះទៀតប្រភពទឹកក្នុងដីជ្រៅ។ ការស្រោចស្រពគួរធ្វើក្នុងអំឡុងពេលស្វាយចេញផ្កា។

### ខ.ការជំរះស្មៅ និងពូនគល់

ត្រូវពិនិត្យមើលពពួកស្មៅ និងរុក្ខជាតិចង្រៃ នៅតាមចន្លោះដើម និងជួរនីមួយៗក្នុងចម្ការស្វាយ បើមានត្រូវកម្ចាត់ចោលដោយដៃ ឬម៉ាស៊ីនកាត់ស្មៅ។ ចំណែកថ្នាំគីមីកសិកម្មកម្ចាត់រុក្ខជាតិចង្រៃ ក៏ត្រូវបានគេប្រើផងដែរ

ដើម្បីបញ្ឈប់ការរីករាលដាលកាន់តែច្រើនឡើងៗរបស់ពពួករុក្ខជាតិចង្រៃ

សារៈប្រយោជន៍នៃការកម្ចាត់ស្មៅ

- ធ្វើឱ្យដីធូរ
- ឫសងាយស្រួលស្រូបយកនូវសារធាតុចិញ្ចឹម
- រក្សាបាននូវបន្ទុកខ្យល់
- បំផ្លាញនូវជម្រកសត្វល្អិត

ជាទូទៅ ការជម្រះស្មៅពូនគល់ គេនិយមធ្វើនៅរដូវប្រាំង ព្រោះក្នុងរដូវនេះ ដីស្រស់ទឹកល្អ ងាយសម្អាត។ ការសំអាតស្មៅអាចធ្វើពី១-២ដងក្នុងមួយឆ្នាំ ពិសេសពេលកូនស្វាយនៅតូចៗមានអាយុពី១-៣ឆ្នាំ ក្នុងពេលធ្វើស្មៅ និង ពូនគល់នេះ គេអាចដាក់ជីបំប៉នតែម្តងក៏បាន ព្រោះអាចចំណេញពេលវេលា ដល់ម្ចាស់ចម្ការ។





## គ. ការដាក់ជីបំប៉ន

ការដាក់ជីបំប៉ន ជាកត្តាសំខាន់ សម្រាប់ការដុះលូតលាស់របស់ដំណាំ នៅឆ្នាំទី១។ ការដាក់ជីអាចធ្វើរៀងរាល់៦-៨ សប្តាហ៍ម្តង ដោយឆ្នាំទី១ ដាក់ក្នុងកម្រិត៤៥០ក្រាមក្នុង១ដើម ឆ្នាំទី២ អាចដាក់រៀងរាល់៣ខែម្តង ក្នុងកម្រិត ៩០០ ក្រាម ក្នុងមួយដើម និងឆ្នាំទី៣ អាចដាក់រៀងរាល់៣ ឬ៤ ខែម្តងក្នុងកម្រិត ១៤០០ ក្រាម ក្នុងស្វាយ១ដើម ។ ចំពោះប្រភេទ

ជីដែលត្រូវណែនាំឱ្យប្រើមាន ជី ៥.៥.៥.៣ និងជី៦.៦.៦.៣។

ការដាក់ជី ១៥.១៥.១៥ ឬ ជី ១៦.១៦.១៦ ក្នុងអត្រា២-៥ គីឡូក្រាមក្នុងស្វាយមួយដើម។ ដំណាំស្វាយមានអាយុពី ៥-១០ ឆ្នាំ ដើម្បីជំរុញឱ្យដងដើមស្វាយលូតលាសបែកមែកធំល្អ ការដាក់ជីកំប៉ុស្ត ក្នុងអត្រា១០-២០គីឡូក្រាមក្នុង១ដើម ដូចជាៈ លាមកសត្វដែលពុកផុយ ជីដែលបានមកពីកាកសំណល់ផ្ទះបាយ ឬផលិតផលធម្មជាតិធម្មជាតិផ្សេងៗ។

**ជីសរីរាង្គ**




**ជីគីមីកសិកម្ម**




ជីអាសូត ហ្វូស្វ័រ និងប៉ូតាស្យូម

## ឃ. ការកាត់តែងមែក

ត្រូវកាត់ចោលមែកដែលអន់ មែកងាប់ មែកមានរោគ ឬជំងឺ មែកមានសត្វល្អិតបំផ្លាញ មែកមានបញ្ញើរក្អែកដុះជាមួយ មែកបំពង់មានខ្នែងតូចៗដុះច្រើនពេក។

### សារៈប្រយោជន៍នៃការកាត់តែងមែក

- កុំឱ្យមែកស្កុកពេក
- ឱ្យខ្យល់ចេញចូលបានល្អ
- បន្ថយភាពសើមកុំឱ្យកើតជំងឺឆ្លង ពិសេសជំងឺផ្សិត

គប្បីធ្វើការកាត់តែងមែកភ្លាមបន្ទាប់ពីប្រមូលផលហើយ ដើម្បីឱ្យស្វាយ

ដុះមែកខ្នែងថ្មីៗ ថ្លោសៗ មាំល្អ។ ចំពោះដើមស្វាយដែលដាំទុក ប្រឡោះជិតគ្នា គួរកាត់ចោលចុងមែកខ្នែងប្រមាណ១-២ ថ្នាំង ទុកតែខ្នែងប៉ុណ្ណោះ។

**កសិករអាចជ្រើសរើសវិធីណាមួយក៏បានដើម្បីអនុវត្តក្នុងចម្ការរបស់ខ្លួន**



ទ្រង់ទ្រាយដើមមុនពេលកាត់តែង

ការកាត់ចោលក្នុងពេលលូតលាស់ទីពីរ កាត់ក្នុងខែសីហា



កាលណាដើមស្វាយអាយុច្រើនត្រូវកាត់ជាដំបូងតាមរូបភាពនេះ





ហើយកាត់តែងក្នុងឆ្នាំបន្តបន្ទាប់មកតាមរូបភាពនេះ ដោយកាត់ចេញផ្នែកលូតលាស់ទីពីរបន្តិចបន្តួច

## II. ជំងឺ និងសត្វល្អិតបំផ្លាញដំណាំស្វាយ

### ១.ជំងឺលើដំណាំស្វាយ

#### ក.ជំងឺអង់ត្រាណូស(AnthracnoseColletotricumgloeosporioides)

#### រោគសញ្ញា

ចំពោះស្លឹកចាស់មធ្យមៈ គេតែងសង្កេតឃើញ មានអុចពណ៌ត្នោតលេចឡើងច្បាស់នៅតាមជាយស្លឹក ដែលក្រោយមក ចំណុចអុចពណ៌ត្នោតនោះ

រីកកាន់តែធំទៅៗ រហូតធ្វើឱ្យខូចស្លឹកអស់ និងចុងក្រោយធ្វើស្លឹកជ្រុះ។

ចំពោះត្រួយៈ បន្ទាប់ពីស្លឹកចាស់មធ្យម ហើយក៏ប្រែទៅជាពណ៌ខៀវខ្ចី ដោយសារភាពសើមបានអូសបន្លាយក្នុងរយៈពេលយូរ ភ្នាក់ងារបង្ករោគចាប់ផ្តើមលូតលាស់នៅលើទងស្លឹក បង្កើតទៅជាសរីរាង្គពណ៌ខ្មៅខូងប្រវែងប្រមាណ១-២ ស.ម ហើយបើសរីរាង្គពណ៌ខ្មៅនេះនៅតែអូសបន្លាយវាអាចធ្វើឱ្យត្រួយងាប់។

ចំពោះផ្កាៈ បើមានភាពសើមនៅតែបន្តភ្នាក់ងារបង្ករោគជំងឺអង់ត្រាណូសអាចធ្វើឱ្យផ្កាប្រែទៅជាពណ៌ត្នោត និងបន្តរីករាលដាលកាន់តែខ្លាំង ទីបំផុតធ្វើឱ្យផ្កាក្រៀមមិនអាចរីកលូតលាស់បាន។

ផ្លែៈក្នុងដំណាក់កាលនេះ ភ្នាក់ងារបង្ករោគ អាចស្តែងចេញឱ្យឃើញនូវចំណុចខូងៗខ្មៅៗជាច្រើនចំណុច និងអាចធ្វើឱ្យទាំងផ្លែចាស់ និង ក្តីបស្វាយត្រូវខូចខាតទាំងអស់។



ជំងឺអង់ត្រាណូសលើផ្លែ



ជំងឺអង់ត្រាណូសលើស្លឹក

## វិធានការការពារ និងកម្ចាត់

- បើរោគសញ្ញា ជាចំណុចតូចៗរាយៗកើតនៅលើស្លឹកចាស់មធ្យម នោះ និងពុំមានផលប៉ះពាល់ទៅលើស្លឹក និងត្រួយទេ វិធានការត្រូវធ្វើ គឺគ្រាន់តែកម្ចាត់ទីជម្រករបស់ពពួកមេរោគចេញពីចម្ការក៏បាន។
- បើស្លឹកខូចខាត ហើយជ្រុះច្រើនគប្បីប្រើថ្នាំគីមីកសិកម្មដើម្បីកម្ចាត់
- ក្នុងដំណាក់កាលចេញផ្កា បើរោគសញ្ញាកើតមាននៅលើទងផ្កានោះសម្គាល់បានថាស្វាយមានជំងឺហើយ ដូច្នេះត្រូវចាត់វិធានការដោយប្រើថ្នាំគីមីកសិកម្មក្នុងការកម្ចាតជំងឺនេះចោល
- ត្រូវបាញ់ថ្នាំគីមីកសិកម្មបន្ទាប់ពីមានភ្លៀងធ្លាក់ជាបន្តបន្ទាប់ជាប់គ្នាពី១-២ថ្ងៃ ដើម្បីបញ្ចៀសការជ្រុះផ្កា
- គប្បីប្រើប្រភេទថ្នាំ 1 បង់ឡាត់ Benlate (Benomyl) 50 % WP ចំនួន ១០-១២ ក្រាម ៤០-៦០ ក្រ លាយទឹក២០លីត្រ គប្បីប្រើថ្នាំគីមីឆ្លាស់គ្នា។

## ខ. ជំងឺផ្សិតម្សៅ (Oidium giferae)

### រោគសញ្ញា

ក្នុងដំណាក់កាលស្លឹកស្វាយចាស់មធ្យម ចៃផ្សិតពណ៌សបានបង្កឱ្យស្លឹកស្វាយដំបូងមានពណ៌លឿង ហើយបន្ទាប់ប្រែទៅជាពណ៌លឿងចាស់។ស្លឹកស្វាយ នៅពេលជំងឺនេះមានការរាតត្បាតខ្លាំង ធ្វើឱ្យជ្រុះដោយស្លឹកខ្លះមានស្រោមម្សៅពណ៌សជាប់ជាមួយផងក៏មាន។

ជាការកត់សម្គាល់ ចំពោះដំណាំស្វាយដែលទទួលការបំផ្លាញពើជំងឺផ្សិតប្រភេទនេះ ភាគច្រើនជាដំណាំស្វាយដែលមានដាំដុះនៅលើដីតំបន់ខ្ពង់រាបមានអាកាសធាតុត្រជាក់ពេញមួយរដូវ។

ក្នុងដំណាក់កាលស្វាយចេញផ្កា ចៃផ្សិតពណ៌សអាចធ្វើឱ្យផ្កាស្វាយគ្រប់ទងជាំ និងជ្រុះ រីឯនៅដំណាក់កាលស្វាយចេញផ្លែ ក៏ដូចគ្នាទៅនឹងដំណាក់កាលស្វាយចេញផ្កាដែរគឺអាចធ្វើឱ្យផ្លែជ្រុះ។

## វិធានការការពារ និងកម្ចាត់

ជាទូទៅការ ការពារដំណាំស្វាយពីជំងឺនេះ ការថែទាំ និងត្រួតពិនិត្យគឺជាកិច្ចការសំខាន់។

ការបាញ់ថ្នាំ Benomyl ក្នុងអំឡុងពេលស្វាយចេញផ្កា តាមធម្មតាគឺគ្រប់គ្រាន់ក្នុងកម្ចាត់ជំងឺផ្សិតម្សៅ ក៏ប៉ុន្តែបើមានការបំផ្លាញធ្ងន់ធ្ងរ ត្រូវប្រើថ្នាំ Benomyl, Dinocap ឬ Sulfur WP. នៅក្នុងអំឡុងពេលស្វាយរៀបចេញផ្កា។

## ២. សត្វល្អិតបំផ្លាញដំណាំស្វាយ

### ❈ ខ្មូតស៊ីរូងដើម

Plocaederus ruficorrnis Newman នៃសណ្ដាន Cerambycidae លំដាប់ស្លាបរឹង Coleoptera

### ១. តំបន់រស់នៅ និងដំណាំជម្រក

ខ្មូតស៊ីរូងដើមប្រភេទនេះ ត្រូវបានគេសង្កេតឃើញ មានវត្តមានបំផ្លាញដំណាំស្វាយពាសពេញតំបន់ដាំដុះស្វាយនៅតំបន់ត្រូពិក ដូចជានៅប្រទេសឥណ្ឌា ថៃ ហ្វីលីពីន ឥណ្ឌូនេស៊ី វៀតណាម និងកម្ពុជា។

### ២.លក្ខណៈរូបរាង្គ និងលក្ខណៈជីវសាស្ត្រ

ខ្មូតស៊ីរូងដើម មានដងខ្លួនពណ៌ត្នោតក្រម៉ៅ ប្រវែងពី ២,៥ ទៅ ៤ស.ម និងមានព្រុយក្បាលពណ៌ក្រហមប្រវែងស្មើដងខ្លួន ចំពោះខ្មូតញី តែចំពោះខ្មូតឈ្មោល គឺព្រុយក្បាលវែងជាងដងខ្លួន។ ខ្មូតមានជើង៦ មានពណ៌ក្រហម ហើយលើថ្លូវមានស្នាមពណ៌ត្នោតក្រម៉ៅ។ លើស្លាបរឹងមានស្នាមអុចជាច្រើន

លៀនមកលើដែលមានពណ៌ខ្មៅ ឬពណ៌ត្នោត។ ទ្រូងខាងមុខ មានទូលតូចៗ មើលទៅគ្រើមៗ និងនៅសងខាងមានបន្លាលៀនចេញមើលទៅប្រៀបដូចស្នែង។ ខ្មូតស៊ីរូងដើមពេញវ័យ អាចរស់នៅបានជាច្រើនខែ ស៊ីទឹកដមផ្កាលម្អងផ្កា ឬស៊ីផ្នែកខ្ចីៗនៃរុក្ខជាតិ។

ពងរបស់ខ្មូតមានរាងមូល ពណ៌ស ដែលត្រូវបានពងដាក់រាយប៉ាយនៅនៅក្នុងស្នាមប្រះនៃសម្បកឈើដំណាក់កាលពងមានរយៈពេលពី២-៣ថ្ងៃ។

ដង្កូវ មានដងខ្លួនពណ៌លឿងស្រាល ក្បាលតូច ដែលជានិច្ចជាកាលរួញចុះក្រោម និងមានជើងតូចឆ្មារដំណាក់កាលដង្កូវមានរយៈពេលរស់នៅយូរហួតដល់៧-៨ ខែ នៅក្នុងដើមឈើ ហេតុនេះហើយទើបការបំផ្លាញរបស់ដង្កូវធ្ងន់ធ្ងរណាស់។ ដង្កូវទើបញាស់មានដងខ្លួនទន់ខ្សោយ ប៉ុន្តែមួយសប្តាហ៍ក្រោយមក ដង្កូវរហ័សរហួន និងធ្វើសកម្មភាពខ្លាំងក្លា។

មុនពេលប្រែក្លាយ ជាដឹកឌឿ ដង្កូវចោះរន្ធជាស្រេច ដើម្បីទុកច្រកចេញមកក្រៅ ក្រោយក្លាយជាខ្មូតពេញវ័យ។ រយៈពេលនៃដំណាក់កាលដឹកឌឿគឺពី១-៣ខែ។

## ៣. ទម្លាប់នៃការរស់នៅ និងការបំផ្លាញ

ខ្មូតស៊ីរូងដើម ពេញវ័យមានការទាក់ទាញដោយពន្លឺអំពូល ជាពិសេសនៅដើមរដូវភ្លៀង គឺជាពេលដែលខ្មូតទើបសកចេញពីដឹកឌឿ។ ខ្មូតញីពងដាក់លើសម្បកឈើ ដែលមានស្នាមប្រះ ឬលើស្នាមរបួសនៃសម្បក។ ដង្កូវក្រោយពេលញាស់ខាំស៊ីសម្បក បង្កើតបានជាចង្អូរបត់ចុះបត់ឡើង។ ដង្កូវកាន់តែធំស៊ីកាន់តែច្រើននិងអាចស្តាប់លឺលាន់ស្នូខាំកកេររបស់ដង្កូវ ដែលក្រោយមកចុះចូលក្នុងដើម និងចោះស៊ីរូងឡើងទៅផ្នែកខាងចុងនៃដើមជួនកាលដង្កូវមិនអាចរកឃើញទីតាំងសមស្របក្នុងការចោះដើមចូល ហើយផ្លាស់ទីមកគល់ដើម្បីចោះស៊ីរូងចូលក្នុងគល់តែម្តង។






*ដង្កូវ និងខ្មូតស៊ីរូងដើមពេញវ័យ*

រន្ធចោះរបស់ដង្កូវ ផ្ទុកពេញទៅដោយអាចម៍ដង្កូវ ហើយផ្សិតក៏ចាប់ផ្ដើមដុះតាមរន្ធរបួសនោះដែរ។ រន្ធអាចចោះតាមបណ្ដោយដើម ឬអាចចោះត្រង់ចូលទៅកណ្ដាលដើមតែម្ដង ហើយទំហំរន្ធពីមួយថ្ងៃទៅមួយថ្ងៃកាន់តែធំតាមទំហំនៃដង្កូវ។ ដើមស្វាយត្រូវបានខ្មូតចោះបំផ្លាញ ជាពិសេសនៅដំណាក់កាលដើមនៅតូច នោះនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់កាលូតលាស់របស់ដំណាំស្វាយដែលបណ្ដាលឱ្យមែកក្រៀម ជ្រុះស្លឹក មាត់រន្ធហូរជ័រនិងមែកមួយចំនួនត្រូវបាក់។

## ៤. វិធីសាស្ត្រទប់ស្កាត់ និងកម្ចាត់

- មិនគួរកាប់សម្បក ឬបកសម្បកស្វាយ ក្នុងគោលបំណងរំញោចឱ្យចេញផ្កាមុនរដូវ ពីព្រោះស្នាមរបួស នឹងទាក់ទាញខ្មូតញីមកពងដាក់។

- យើងអាចប្រើអំពូល ដើម្បីចាប់ខ្ទួតពេញវ័យសម្លាប់ចោល
- ឧស្សាហ៍អង្កេតដំណាំស្វាយហើយបើឃើញមានរន្ធចោះថ្មីៗប្រើដែកខួងចោះ ហើយញុកថ្នាំម្សៅ (ថ្នាំកម្ចាត់សត្វល្អិត) រួចយកដីបិទរន្ធ។ បើមែកស្វាយមានខ្ទួតបំផ្លាញច្រើន ត្រូវកាត់មែកទាំងនោះទៅដុតកម្ទេចចោល ដើម្បីកម្ចាត់ប្រភពចង្រៃដែលបានបន្សល់ទុកកាលពីរដូវមុន។
- ក្រៅពីនេះ យើងអាចប្រើដើម ឬមែកស្វាយស្ងួត ដាក់រាយក្នុងចម្ការស្វាយដើម្បីទាក់ទាញខ្ទួតពេញវ័យមករស់នៅរួចប្រមូលកម្ចាត់ចោល។

## ❋ ដង្កូវស៊ីរូងមែក

Chlumetia transversa Walker នៃសណ្ឋាន Gelechidae លំដាប់ស្លាបស្រកា Lepidoptera

### ១. លក្ខណៈរូប និងលក្ខណៈជីវសាស្ត្រ

សត្វពេញវ័យ គឺជាប្រភេទមេអំបៅពណ៌ត្នោតក្រហម មានដងខ្លួនប្រវែងពី ៨ - ១០ ម.ម និងត្រដាងស្លាបទំហំពី ១៧-២០ ម.ម ។ ស្លាបមុខមានពណ៌ទឹកប្រាក់ផ្លេកៗ គល់ស្លាបមានពណ៌ស្រអាប់ជាង រីឯនៅចុងស្លាបមានឆ្នូតកាត់ទទឹងស្លាប និងមានអុចខ្មៅមួយជួរនៅគែមនៃស្លាប។ ស្លាបក្រោយមានពណ៌ស្រាលជាងស្លាបមុខ។

មេអំបៅទម្លាក់ពង រាយប៉ាយលើស្លឹក និងលើពន្លក ហើយក្រោយពងបាន២-៣ថ្ងៃ វានឹងញាស់ជាដង្កូវ។

ដង្កូវមានពណ៌ផ្កាកូឡាប និងនៅពេលធំអតិបរិមា មានប្រវែងពី២ ទៅ៣ ម.ម ហើយដំណាក់កាលដង្កូវមានរយៈពេលលូតលាស់ពី៨-១៥ ថ្ងៃ។

ដឹកឌឿមានពណ៌ត្នោត ហើយរយៈពេលនៃដំណាក់កាលដឹកឌឿ គឺពី៨-១២ ថ្ងៃ។



*វដ្តជីវិតដង្កូវស៊ីរូងមែក និងការបំផ្លាញ*

## ២. ទម្លាប់នៃការរស់នៅ និងការបំផ្លាញ

មេអំបៅប្រភេទនេះ មានការទាកទាញខ្លាំងដោយពន្លឺអំពូលភ្លើងជាពិសេស នាពេលយប់រដូវរនោច និងគ្មានខ្យល់។ មេអំបៅទម្លាក់ពងនៅពេលយប់ដាក់រាយប៉ាយលើពន្លក និងស្លឹកខ្ចី។

ក្រោយពេលញាស់ ដង្កូវចោះរូងចូលតាមទ្រនុងស្លឹកខ្ចី ហើយប្រមាណ ២ថ្ងៃក្រោយមក ដង្កូវធំចាប់ផ្ដើមចោះក្នុងពន្លកត្រួយ។ ដង្កូវចោះស៊ីតែ១ថ្នាំង ប៉ុន្តែបើថ្នាំងស្វាយខ្ចី(ខ្ចីជាង៥ស.ម) ដង្កូវចោះស៊ីឆ្លងចូលថ្នាំងផ្សេងទៀត។ ស្លឹកនៃខ្នែងដែលត្រូវដង្កូវចោះលើទងស្លឹក ក្លាយជាក្រៀម ស្រពោន និងពុំមានផ្កាទេ ហើយបើដង្កូវចោះលើទងផ្កា នឹងបណ្ដាលឱ្យផ្កាជ្រុះអស់។ ដង្កូវប្រែក្លាយដឹកឌឿនៅក្នុងសម្បុរឈើ លើផ្កាក្រៀមឬក្នុងដី

## ៣. វិធីសាស្ត្រទប់ស្កាត់ និងកម្ចាត់

កាត់ខ្នែងដែលត្រូវដង្កូវចោះបំផ្លាញ មុននឹងប្រើថ្នាំ។ គួរប្រើពី១ - ២ ដង ក្នុង១ខែ នៅពេលដែលផ្លែលាស់ត្រួយខ្ចី។ ថ្នាំដែលប្រើត្រូវជ្រើសរើសយក ថ្នាំដែលមានសកម្មភាពជ្រាបចូលជាប្រព័ន្ធ។

## ❋ ដង្កូវស៊ីគ្រាប់ស្វាយ

Noorda albizonalis Hampson ឈ្មោះផ្សេងទៀតគឺ Deanolis albizonalis Hampson នៃសណ្ឋាន pyralidae លំដាប់ Lepidoptera

ដង្កូវស៊ីរូងគ្រាប់ស្វាយ គឺជាប្រភេទដង្កូវបំផ្លាញធ្ងន់ធ្ងរមួយដែលគេ សង្កេតឃើញលើចម្ការស្វាយនៅប្រទេសកម្ពុជាយើង។ នៅបណ្តាប្រទេសដែលដាំដុះស្វាយមួយចំនួនទៀត ក៏ជួបប្រទះបញ្ហាដូចជាប្រទេសយើងដែរ ដូចជា ប្រទេសឥណ្ឌា ថៃ ហ្វីលីពីន ឥណ្ឌូនេស៊ី វៀតណាម គេមិនទាន់រកឃើញនូវ ដំណាំជម្រករបស់ដង្កូវផ្សេងទៀតក្រៅពីដំណាំស្វាយនៅឡើយ។

## ១. លក្ខណៈរូបរាង្គ និងលក្ខណៈជីវសាស្ត្រ

មេអំបៅមានប្រវែងពេលត្រដាងស្លាបមានប្រវែង ២៧-៤ ម.ម ពណ៌ត្នោត ហើយស្លាបមុខមានពណ៌ត្នោត និងស្លាបក្រោយមានពណ៌សប្រផេះ។

- ពងមានរាងពងក្រពើ ហើយពងថ្មីៗមានពណតស ដែលក្រោយមក ប្រែជាពណ៌កូឡាប និងរៀបញាស់ប្រែជាពណ៌ផ្កាឈូកស្រអាប់។ អង្កត់ផ្ចិតនៃពងមានប្រវែងប្រមាណ០,២-០,៣ ម.ម ហើយកម្រនឹង មើលឃើញវាក្នុងលក្ខខណ្ឌដាំដុះណាស់។
- ដង្កូវទើបញាស់មានប្រវែង ០,៥-០,៦ ម.ម ពណ៌ស និងមានឆ្នូតកាត់ ទទឹងពណ៌ក្រហម។ នៅដំណាក់កាលទី២ ឆ្នូតទទឹងលើដងខ្លួនដង្កូវ រីកធំឡើងៗហើយដង្កូវមានប្រវែង០,៧-០,៨ ម.ម ។ ចូលដល់ដំណាក់ កាលទី៣ដង្កូវមានប្រវែងពី១-១,២ ស.ម និងដំណាក់កាលទី៤ មាន

ប្រវែង ១,៣-១,៥ ស.ម និងដំណាក់កាលទី៥មានប្រវែង ១,៨-២,២ ស.ម ហើយបណ្ដាឆ្នូតលើខ្នងលេចចេញច្បាស់ៗ។ នៅពេលប្រែក្លាយជាដឹកឌឿ ពោះនៃដង្កូវប្រែជាពណ៌បៃតងស។

- ដឹកឌឿមានប្រវែង១១-១២ ម.ម ហើយដឹកឌឿថ្មីៗមានពណ៌លឿងស្រាល ដែលក្រោយមកប្រែជាពណ៌លឿងត្នោត ហើយរយៈពេលនៃដំណាក់កាលដឹកឌឿគឺពី ១៤ - ១៦ ថ្ងៃ វដ្តជីវិតរបស់ដង្កូវស៊ីគ្រាប់ស្វាយ អូសបន្លាយពី៣៨-៤៣ ថ្ងៃ ដែលក្នុងដំណាក់កាលពងមានរយៈពេលពី៤-៥ថ្ងៃ ដំណាក់កាលដង្កូវមាន៥ ដំណាក់កាល ហើយអាចសកចំនួន៤ដង ប្រើរយៈពេលអស់ ១៤-១៦ថ្ងៃដំណាក់កាលដឹកឌឿមានពី១១-១៧ថ្ងៃ ដំណាក់កាលពេញវ័យមានរយៈពេលពី៦-៧ ថ្ងៃ។ ដង្កូវនេះបំផ្លាញច្រើនលើស្វាយដែលផ្លែតាមរដូវ និងមានការបំផ្លាញតិចតួចលើចម្ការស្វាយដែលផ្លែខុសរដូវ។




*វដ្តជីវិតដង្កូវស៊ីរូងគ្រាប់ស្វាយ និងការបំផ្លាញ*

## ២. ទម្លាប់នៃការរស់នៅ និងការបំផ្លាញ

មេអំបៅធ្វើសកម្មភាព និងពងនៅពេលយប់ ដាក់លើទងនៃផ្លែក្រោមស្រទាបក្រៀមៗនៃទងផ្លែ ដែលពិបាកក្នុងការពិនិត្យឃើញ។

ដង្កូវចាប់ផ្ដើមចោះបំផ្លាញគ្រាប់ស្វាយ នៅពេលផ្លែស្វាយមានទំហំប៉ុនមេជើងរហូតដល់ផ្លែធំជិតប្រមូលផល។ ក្រោយពេលញាស់ ដង្កូវវារចុះទៅផ្នែកខាងក្រោមនៃផ្លែស្វាយ ហើយចុះចូលទៅខាងក្នុង ស៊ីស៊ីផ្នែកសាច់នៃផ្លែស្វាយរួចចោះចូលទៅក្នុងគ្រាប់ស្វាយដែលនៅខ្ចី។ ក្នុងផ្លែស្វាយមួយផ្លែអាចមានដង្កូវច្រើនក្បាលចោះចូលបំផ្លាញ និងពេលស៊ីអស់គ្រាប់ស្វាយ ដង្កូវវារចេញទៅរកផ្លែស្វាយជិតខាងហើយចោះបំផ្លាញទៀត។នៅពេលដង្កូវធំអស់កម្រិតវាខ្ទាក់ស្លូត្រទម្លាក់ខ្លួនចុះដី ហើយប្រែក្លាយដឹកឡើនៅក្នុងដី ដែលមានរយៈពេលប្រមាណ២ សប្ដាហ៍។

ស្នាកស្នាមនៃផ្លែស្វាយត្រូវបានដង្កូវចោះបំផ្លាញ គឺនៅផ្នែកគូទ ហើយនៅក្បែររន្ធនោះមានស្នាមរលួយខ្មៅ។

## ៣. វិធីសាស្ត្រទប់ស្កាត់ និងកម្ចាត់

- ប្រើថ្នាំការពារផ្លែស្វាយនៅពេលផ្លែមានទំហំប៉ុនមេដៃ ឬមេជើង និងប្រើថ្នាំនៅពេលផ្លែស្វាយលើដើមត្រូវបានបំផ្លាញប្រមាណ២%។ ដូច្នេះត្រូវឧស្សាហ៍តាមដាន ពិនិត្យចម្ការស្វាយ និងអត្រាផ្លែស្វាយដែលទទួលរងការបំផ្លាញ
- ប្រមូលផ្លែស្វាយដែលត្រូវទទួលរងការបំផ្លាញ យកទៅកម្ទេចចោលមុនពេលដង្កូវវិវត្តន៍ទៅជាដឹកឡើ
- ស្រោបផ្លែស្វាយដោយថង់ក្រដាស់ដើម្បីការពារការចោះបំផ្លាញ
- កាត់តែងមែក បេះបន្ថយចំនួនផ្លែលើដើម រក្សាទុកផ្លែត្រឹមចំនួនកំណត់ដើម្បីឱ្យស្វាយផ្ដល់ផលច្រើន និងងាយកម្ចាត់សត្វល្អិតបំផ្លាញ

## ❈ ជន្ទរុយចោះផ្លែ

Dacus dorsalis Hendel មានឈ្មោះផ្សេងទៀតគឺ Bactrocera dorsalis Hendel នៃសណ្ឋានTrypetidae លំដាប់ស្លាបពីរ Diptera

### ១. តំបន់រស់នៅ និងដំណាំជម្រក

ដង្កូវរុយចោះផ្លែ មានវត្តមានបំផ្លាញនៅបណ្ដាប្រទេសដែលដាំដុះដំណាំឈើហូបផ្លែក្នុងតំបន់អាស៊ីអគ្នេយ៍ក្រៅពីដំណាំស្វាយ ដង្កូវរុយចោះផ្លែបំផ្លាញលើដំណាំហូបផ្លែច្រើនប្រភេទផ្សេងទៀតដូចជា ផ្លែក្រូចពោធិសាត់ ក្រូចឆ្មារ ក្រូចខ្វិច ត្របែក ខ្នុរ មៀន..។

### ២.លក្ខណៈរូបរាង្គ និងលក្ខណៈជីវសាស្ត្រ

រុយពេញវ័យមានដងខ្លួនប្រវែងពី៦-៩ ម.ម និងពេលត្រដាងស្លាបមានប្រវែង១៣ ម.ម ។ ក្បាលរុយមានពណ៌លឿង មានរាងពាក់កណ្ដាលរង្វង់ផ្ទៃមុខមានពណ៌ក្រហមត្នោត និងមានអុចពណ៌ខ្មៅចំនួន៦ ចំណុចហើយផ្នែកក្រោយនៃក្បាលមានរោមល្អិតៗច្រើន។ ព្រុយក្បាលខ្លីដែលមានថ្នាំងចំនួន៣៣ ហើយថ្នាំងចំនួន២ ខាងដើម មានរាង្គតូចហើយខ្លី និងថ្នាំងក្រោយៗមានទំហំធំវែងៗ។ ផ្នែកទ្រូងមានពណ៌ក្រហមត្នោត ឬត្នោតស្រអាប់។ សងខាងទ្រូងមានស្នាមអុចចំនួនពីរពណ៌លឿង ហើយនៅត្រង់ចំណុចភ្ជាប់ជាមួយផ្នែកពោះមានស្នាមពណ៌លឿងធំមួយ។ ពោះមានឆ្នូតទទឹងចំនួន២ពណ៌លឿង ឆ្នូតលើតូច និងឆ្នូតក្រោមធំ ហើយនៅចំកណ្ដាលឆ្នូតទាំងពីរនេះមានឆ្នូតពណ៌ខ្មៅមួយទៀត និងថែមទាំងមានឆ្នូតបណ្ដោយខ្លួនមួយទៀតដែលតពីឆ្នូតលឿងទី២ មកដល់កន្ទុយ ដោយបង្កើតបានជារាង្គដូចអក្សរតេ (T) ។ ស្លាបមានពណ៌ប្រផេះ ហើយនៅក្បែរទ្រនុងស្លាបខាងមុខ មានពណ៌ស្រអាប់ជាង ។ បាតជើងមានថ្នាំងចំនួន៥ ថ្នាំងខាងចុងមានក្រចកពីរ និងដុះស្តោតធំមួយ។ ផ្នែកភ្លៅនៃជើងទាំងបីគូរ មានពណ៌ក្រហម ចំណែកឯថ្នាំងដទៃមានពណ៌

លឿង។




*រុយចោះផ្លែ និងការបំផ្លាញ*

យើងអាចសម្គាល់ភាពខុសគ្នារវាងរុយញី និងរុយឈ្មោល ដោយរុយញី មានដងខ្លួនធំជាង និងមានបំពង់សម្រាប់ទម្លាក់ពងវែង។ ក្រោយពីសកជារុយពេញវ័យបានពី ៧ - ១៥ ថ្ងៃ រុយចាប់ផ្តើមពង ហើយអាចរស់នៅបានប្រមាណពី ២០-៤០ថ្ងៃ រុយញីមួយក្បាលអាចពងបានពី១៥០-២០០គ្រាប់ ដែលពងជាមធ្យម៥០គ្រាប់ក្នុង១ថ្ងៃ និងពងក្នុងរយៈពេល៣០ថ្ងៃ ។

ពងរបស់រុយ មានរាងដូចគ្រាប់អង្ករ ប្រវែងប្រមាណ១ម.ម ហើយពងថ្មីៗ មានពណ៌ទឹកដោះគោ ដែលនៅពេលរៀបញាស់ ពងប្រែទៅជាពណ៌លឿងស្រាល។ រយៈពេលនៃដំណាក់កាលពងគឺពី២-៤ថ្ងៃ។

ដង្កូវរុយទើបញាស់មានប្រវែងប្រមាណ១,៥ម.ម លុះដល់ដង្កូវធំជាអតិបរិមាមានប្រវែងពី៦-៨ម.ម និងមានពណ៌លឿងស្រាល។ ដង្កូវមានដំណាក់

កាលលូតលាស់ចំនួន៣ ដែលវិវត្តន៍ក្នុងរយៈពេលពី១០-១៤ថ្ងៃ

ដឹកឡឿមានរាងទ្រវែង ហើយដឹកឡឿថ្មីៗមានពណ៌លឿងត្នោត និងក្រោយមកប្រែជាពណ៌ក្រហមត្នោតដឹកឡឿមានប្រវែង ៥-៧ម.ម ក្នុងដំណាក់កាលនេះមានរយៈពេលពី៧-១០ថ្ងៃ។

## ៣. ទម្លាប់នៃការរស់នៅ និងការបំផ្លាញ

រុយញីប្រើបំពង់ពងមុតស្រួចរបស់ខ្លួន ចោះទម្លុះសម្បកផ្លែឈើ ហើយពងដាក់ត្រង់ស្រទាប់ចន្លោះសម្បក និងសាច់ផ្លែឈើ។ ពងរុយត្រូវបានទម្លាក់ដាក់ជាកញ្ចុំក្នុងរន្ធសម្បកដែលមេរុយបង្កើតឡើង។ ដង្កូវរុយដែលញាស់ចេញមកចាប់ផ្តើមចោះស៊ីសាច់ផ្លែឈើ បណ្តាលឱ្យស្អុយរលួយ។ ក្រោយពេលដង្កូវរុយញាស់ចេញស្នាមចោះរបស់មេរុយចាប់ផ្តើមជោរទឹក និងក្រោយមកចាប់ផ្តើមជាំរលួយ។ នៅពេលដង្កូវធំ បើផ្លែឈើដែលដែលវាស្នាក់នៅជ្រុះមកដី ដង្កូវនឹងចេញមកដី ហើយប្រែក្លាយទៅជាដឹកឡឿ តែបើផ្លែឈើនោះមិនជ្រុះទេ ដង្កូវរុយខ្ទាក់សូត្រសម្រូតខ្លួនចុះមកដី ដើម្បីប្រែក្លាយជាដឹកឡឿដែរ។ ដង្កូវរុយប្រែក្លាយជាដឹកឡឿនៅក្នុងដីជម្រៅប្រមាណ៣-៧ ស.ម ។

## ៤. វិធីសាស្ត្រទប់ស្កាត់ និងកម្ចាត់

- ប្រមូលផ្លែឈើដែលជ្រុះយកទៅឱ្យសត្វស៊ី ឬយកទៅកប់ដី ពីព្រោះផ្លែឈើទាំងនេះជាជម្រករបស់ដង្កូវ
- ប្រើប្រាស់អន្ទាក់ភេទ (Sex pheomone) ដើម្បីកាត់បន្ថយការបន្តពូជរបស់រុយ ឬប្រើប្រភេទផ្អាក់ចំណី
 ដើម្បីប្រមូលរុយពេញវ័យ
- ប្រើថ្នាំកម្ចាត់ដង្កូវរុយ ដោយប្រភេទថ្នាំដែលមានកម្រិតពុលទាបចំពោះមនុស្ស-សត្វ។

## III. ការប្រមូលផល

មុនធ្វើការប្រមូលផល ចំបាច់ត្រូវពិនិត្យមើលសេចក្តីត្រូវការរបស់ទីផ្សារ ដើម្បីធ្វើផែនការប្រមូលផលប្រកបដោយគុណភាព ។ សម្ភារសម្រាប់ប្រមូលផលត្រូវមានគ្រប់លក្ខណៈ និងសមស្រប ដើម្បីជៀសវាងបន្ថយការខូចខាតផ្លែស្វាយ ដូចជា បង្កឱ្យជាំ ស្អុយ ដែលបណ្តាលមកពីការហូរជ័រ។

បន្ទាប់ពីបេះផ្លែស្វាយបានមួយដើមហើយ ត្រូវដាក់ក្នុងកញ្ច្រែង ឬជាលជាដើម ហើយត្រូវបញ្ជូនទៅដាក់នៅទីកន្លែងណាមួយសមស្រប រួចធ្វើការជ្រើសរើស ដោយចាត់ជាចំណាត់ថ្នាក់ រួចរៀបចូលកែស។ ជាមួយគ្នានេះដែរ ដើម្បីរក្សាផ្លែស្វាយឱ្យមានគុណភាពទាំងពណ៌ និងរសជាតិ ត្រូវដាក់ថ្នាំសម្លាប់មេផ្សិត។ ដើម្បីសម្លាប់មេរោគក្រោយពេលប្រមូលផលរួច។



ការប្រមូលផលត្រូវធ្វើដោយប្រុងប្រយ័ត្ន



ការធ្វើចំណាត់ថ្នាក់ និងវេចខ្ចប់

**បញ្ជាក់:**

មុនពេលធ្វើចំណាត់ថ្នាក់ផ្លែស្វាយ ត្រូវកាត់ទងដោយរក្សាទុកត្រឹម ២-៣មីលីម៉ែត្រពីផ្លែ ដើម្បីឱ្យជ័រហូរចេញពីផ្លែ។ របៀបធ្វើ ដំបូងត្រូវកាន់ទង

បន្ទាប់មកកាត់ បន្ទាប់មកទៀតដំរាប់ផ្លែស្វាយលើក្រដាស់ ឬបាវស្អាត ដោយដាក់ក្បាលចុះក្រោម ទុកឱ្យជ័រហូរចេញពីផ្លែលុះត្រាស្ងួត
ទើបដាក់ចូលកែស៕

## ឯកសារយោង:

១. ការគ្រប់គ្រង និងថែទាំចម្ការស្វាយដោយប្រើវិធីសាស្ត្រចម្រុះលើកត្តាចង្រៃ គណៈកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែ ខេត្តតំបន់ពាយ័ព្យ ១៩៩៧
២. ម៉ូឌុលបណ្តុះបណ្តាលស្តីពីដំណាំឈើហូបផ្លែ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ២០១៣
៣. ព្រឹត្តិបត្រព័ត៌មានដំណាំស្វាយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម២០១៤
៤. សត្វចង្រៃបំផ្លាញដំណាំសំខាន់ៗ នៅកម្ពុជា បណ្ឌិត ជាង ហុង លោក ងិន ឆាយ ២០១៤៕